ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**COMPANY NAME: REBECCA HAIR PRODUCTS (CAMBODIA) CO., LTD**

កិច្ចព្រមព្រៀង

## ស្តីពីកិច្ចប្រជុំពិភាក្សាលើករណីស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតរយៈពេល ៣០ ថ្ងៃ

ថ្ងៃចន្ទ ០១រោច ខែអាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី ២១ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង ០៨:៣០នាទីព្រឹក មានកិច្ចប្រជុំមួយនៅរោងចក្រ រ៉េបឺការ ហែរ ប្រដាក់ (ខេមបូឌា) ខូអិលធីឌី មានអាសយដ្ឋានស្ថិតនៅភូមិ ពូធឿង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដោយមានលោក YANG HAITAO ជានាយករោងចក្រ បានបើកកិច្ចប្រជុំជាមួយលោក សាលីន កាម៉ាល់ជាប្រធានរដ្ឋបាល និងបងប្អូនដែលជាប្រតិបុគ្គលិកចំនួន ១០រូបផ្សេងទៀត ដែលតំណាងអោយកម្មករ កម្មការិនីសរុប ៤៤៣ នាក់។

ជាកិច្ចចាប់ផ្តើមលោក YANG HAITAO ជាប្រធានអង្គប្រជុំ បានមានមតិស្វាគមន៍ដល់បងប្អូនប្រតិភូបុគ្គលិកទាំងអស់ដែលបានចូលរួម និងបើកកិច្ចពិភាក្សាអំពីការព្យួរកិច្ចសន្យាការងាររបស់កម្មករ និយោជិតចំនួន ២១៣ នាក់សម្រាប់រយៈពេល ៣០ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០២៣ ដល់ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ២០២៣ ដោយសារស្ថានភាព បញ្ហាបញ្ជាទិញរបស់អតិថិជនមានការធ្លាក់ចុះយ៉ាងខ្លាំង។

ក្រោយការពិភាក្សាគ្នា រវាងភាគីតំណាងក្រុមហ៊ុន និងប្រតិភូបុគ្គលិករួចមក ភាគីទាំងពីរបានឯកភាពផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិតម្នាក់ៗចំនួន ៣០ដុល្លារ ក្នុងកំឡុងពេលនៃការព្យួរនេះ និងបើកជូនបងប្អូនកម្មករនិយោជិតនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣។ ចំពោះប្រាក់ឧបត្ថម្ភរបស់រដ្ឋាភិបាលអនុវត្តតាមសេចក្តីណែនាំលេខ ០២០/២៣ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០២៣។

កិច្ចពិភាក្សាបានបញ្ចប់ នៅវេលាម៉ោង ០៩:១០ នាទីព្រឹកនៅថ្ងៃខែឆ្នាំដដែល ក្រោមស្មារតីយោគយល់គ្នា និងទទួលយកនូវស្មារតីនៃកិច្ចព្រមព្រៀងនេះ។

ថ្ងៃចន្ទ ០១រោច ខែអាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ខេត្តព្រះសីហនុ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០២៣

ភាគីទាំងពីរបានឯកភាព និងផ្តិតមេដៃទុកជាភស្តុតាង

នាយករោងចក្រ

ប្រតិភូបុគ្គលិក

ប៊ុន ធារី ណាត ស្រីចាន់ ហ៊ុច កញ្ញា ហ៊ុន ចិន្តា សា ចន្ទមករា

ឈឿន ស្រីមុំ ណោម ឌីវ៉ាន់